**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គ្រឹះស្ថានអង្គរ**

លេខៈ ០១៩ ...គសអ.....

ថ្ងៃពុធ ១២រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអនុវត្តគោលនយោបាយលើកទឹកចិត្ត នៃការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ

គ្រឹះស្ថានអង្គរមានកិត្តិយស សូមគោរពជម្រាបជូន សាធារណៈជនជាតិ អន្តរជាតិ គ្រប់ប្រតិបត្តិករទេសចរណ៍ ព្រមទាំងភ្ញៀវទេសចរបរទេសទាំងអស់មេត្តាជ្រាបថា ដើម្បីសម្រួលដល់វិស័យទេសចរណ៍ និងជានាភាពទាក់ទាញភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានអង្គរ ក៏ដូចជាមកព្រះរាជាណាចក្រកម្ពុជា ក្នុងកំឡុងពេលមានវិបត្តិនៃជំងឺកូវីដ-១៩(COVID-19) រាជរដ្ឋាភិបាលបានសម្រេចផ្តល់គោលនយោបាយលើការលើកទឹកចិត្តដល់ភ្ញៀវទេសចរបរទេស នូវការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ គិតចាប់ពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ មានដូចខាងក្រោម÷

ក. ប្រភេទបណ្ណធម្មតា

១- ទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ០១ថ្ងៃ អាចចូលទស្សនាបានរយៈពេល ០២ថ្ងៃ
២- ទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ០៣ថ្ងៃ អាចចូលទស្សនាបានរយៈពេល ០៥ថ្ងៃ
៣- ទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ០៧ថ្ងៃ អាចចូលទស្សនាបានរយៈពេល ១០ថ្ងៃ

ខ. ប្រភេទបណ្ណរយៈពេលវែង ( ភ្ញៀវបរទេសដែលមានទិដ្ឋាការរយៈពេល០៣ខែឡើងទៅ )

១- ទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គររយៈពេល០១ខែ អាចចូលទស្សនាបានរយៈពេល ០២ខែ
២- ទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គររយៈពេល០៣ខែ អាចចូលទស្សនាបានរយៈពេល ០៦ខែ
៣- ទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គររយៈពេល០៦ខែ អាចចូលទស្សនាបានរយៈពេល ១២ខែ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនជាតិ អន្តរជាតិ គ្រប់ប្រតិបត្តិករទេសចរណ៍ ព្រមទាំងភ្ញៀវទេសចរបរទេសទាំងអស់មេត្តាជ្រាប និងអនុវត្តតាមកាលបរិច្ឆេទដូចបានជម្រាបជូនខាងលើ។ -

**គ្រឹះស្ថានអង្គរ**

ផ្លូវ៦០ម៉ែត្រ ភូមិត្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
St 60m, Treang Village, Slor Kram Commune, Siem Reap City, Siem Reap Province, Kingdom of Cambodia
www.angkorenterprise.gov.kh
ទូរស័ព្ទលេខ: ០១២-៦០៦-៨៥២, ០៦៩-៥៦៣-៣៤៦
Phone:855-12-606-852, 855-69-563-346
Email: angkorenterprisekh@gmail.com